# មាគ៌ានៃជំនាន់ដើម

និពន្ធ និងរៀបរៀងដោយ

សមាគមស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ

ស្វែងរកប្រាជ្ញា ស្គាល់ព្រះជាម្ចាស់ គោរពសេចក្ដីពិត

www.facebook.com/SeekingtheWisdomofJesusinKhmer

រូបថតគំរបខាងក្រៅដោយលោក អ៊ីថាន់ ក្រោលី (Ethan Crowley)

© រក្សាសិទ្ធិ ២០១៥

# *ភាគទី១ – សេចក្តីលំនាំដើម*

មនុស្សគ្រប់ជាតិសាសន៍ដែលរស់នៅលើផែនដីនេះ តែងតែមានជំនឿ និងសាសនារបស់ខ្លួន តែជំនឿ និងសាសនាទាំងនោះ តែងតែផ្លាស់ប្រែពីមួយជំនាន់ ទៅមួយជំនាន់ជានិច្ច។ មនុស្សយើងមិនអាចរក្សាសេចក្តីជំនឿ ឬទំនៀមទំលាប់ប្រពៃណីរបស់ខ្លួន ឲ្យបានស្ថិតនៅដដែលជារៀងរហូតបាននោះឡើយ ពីព្រោះ ពេលមនុស្សមួយជំនាន់បានស្លាប់បាត់ទៅ នោះមនុស្សជំនាន់ក្រោយក៏បានអភិវឌ្ឍន៍ជំនឿរបស់ខ្លួន ដោយបញ្ចូលគំនិតថ្មីៗ ដែលគេគិតឃើញថាល្អត្រឹមត្រូវ បន្ថែមទៅលើជំនឿចាស់របស់មនុស្សជំនាន់មុន។ លុះរាប់រយឆ្នាំកន្លងមក ជំនឿចាស់របស់ជីដូនជីតាក៏បានរលាយបាត់អស់ ដោយជំនួសមកវិញនូវជំនឿថ្មី។

នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ក៏មានបញ្ហាដូចគ្នានេះបានកើតឡើងដែរ។ បុព្វបុរសដំបូងរបស់ខ្មែរបានជឿថា ទោះបីជាដូនតាស្លាប់បាត់បង់ខាងរូបកាយហើយក៏ដោយ ក៏ព្រលឹងនៃដូនតាទាំងនោះបន្តរស់នៅក្បែរៗក្នុងភូមិ ដើម្បីថែរក្សាមើលសុខទុក្ខកូនចៅរបស់ខ្លួនជានិច្ច។[១] តែនៅពេលដែលប្រពៃណី និងទំនៀមទំលាប់របស់ឥណ្ឌាបានហូរចូលមកក្នុងស្រុកខ្មែរ នោះជំនឿទៅលើព្រហ្មញ្ញសាសនាក៏បានចូលមកដែរ។[២] នៅក្នុងសាសនានេះបានបង្រៀនថា ព្រលឹងដូនតាដែលបានស្លាប់ទៅ មិនស្ថិតនៅក្បែរយើងរហូតនោះទេ គឺពួកគេបានចាប់ជាតិទៅវិញហើយ។ ជំនាន់ក្រោយមកទៀត

---

(១) យោងតាមសៀវភៅ *ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ* ភាគទី១ និពន្ធដោយលោក មៀច ប៉ុណ្ណ បោះពុម្ពឆ្នាំ ២០០៧ ទំព័រ ១២៤

(២) យោងតាមសៀវភៅ *ជនជាតិខ្មែរ* ភាគទី១ និពន្ធដោយលោក Paul Brunon និងស៊ុនហេង ម៉េងឈាង បោះពុម្ពឆ្នាំ ២០០៨ ទំព័រ ៧

ក៏បានកែច្នៃជំនឿទៅលើព្រហ្មញ្ញសាសនា ដោយបញ្ចូលទ្រឹស្តីថ្មីហៅថា «ទេវរាជ» គឺគេបានចាត់ទុកស្តេចជាព្រះមហាក្សត្រផង ជាព្រះអាទិទេពផង។[៣] កាលពីមុនមិនដែលមានទ្រឹស្តីទេវរាជក្នុងព្រហ្មញ្ញសាសនាទេ តែពួកគេបានលាយចំរុះគំនិតថ្មីនេះជាមួយនឹងជំនឿចាស់ បង្កើតបានជាជំនឿថ្មីមួយ។ រាប់រយឆ្នាំកន្លងមកទៀត ស្តេចខ្មែរមួយអង្គបានងាកចេញពីមាគ៌ាព្រហ្មញ្ញសាសនា ដែលទ្រង់បានទទួលពីរាជវង្សមុនៗរបស់ព្រះអង្គ ហើយបែរមកគោរពបូជាពុទ្ធសាសនានិកាយមហាយានវិញ តែទ្រង់បានរក្សាទ្រឹស្តីទេវរាជដដែល។[៤] ដូចគ្នានេះដែរ ក្នុងពុទ្ធសាសនាមិនដែលមានទ្រឹស្តីទេវរាជទេ តែព្រះអង្គបានលាយចំរុះពុទ្ធសាសនា ជាមួយនឹងជំនឿនៃរាជវង្សមុនៗរបស់ទ្រង់ ហើយបង្កើតបានជំនឿថ្មីមួយទៀត ដូចជាបុព្វបុរសរបស់ទ្រង់ធ្លាប់ធ្វើពីមុនដែរ។ នៅជំនាន់ក្រោយៗមកទៀត ជីដូនជីតាខ្មែរបានកំណត់ថា ពុទ្ធសាសនានិកាយហីនយាន ជាសាសនារបស់រដ្ឋ។ គោលលទ្ធិដ៏ធំមួយក្នុងពុទ្ធសាសនានិកាយហីនយានបានបង្រៀនថា គ្មានព្រះអាទិទេព អ្នកតា ឬព្រលឹងវិញ្ញាណឯណា ដែលជាទីពឹងសម្រាប់មនុស្សនោះឡើយ គឺមានតែ «ខ្លួនទីពឹងខ្លួន»។[៥] តែនៅសម័យបច្ចុប្បន្ននេះ ដោយបានទទួលឥទ្ធិពលនៃជំនឿចិនទៀត ខ្មែរជាច្រើនបាននិយមគោរពព្រលឹងវិញ្ញាណកុងម៉ាវិញ ដែលជំនឿនេះស្រដៀងគ្នាទៅនឹងជំនឿពីបុរាណទាក់ទងទៅនឹងព្រលឹងដូនតាដែរ។ ក្នុងជំនាន់អនាគត តើជនជាតិខ្មែរនឹងជឿទៅលើអ្វីទៀត?

នៅលើពិភពលោកយើងសព្វថ្ងៃនេះ ជំនឿ និងសាសនាដែលត្រូវបានគេបោះបង់ចោល ស្ទើរតែរាប់មិនអស់ បើប្រៀបធៀបទៅនឹងចំនួននៃជំនឿ និងសាសនាដែល

---

(៣) យោងតាមសៀវភៅ *ជនជាតិខ្មែរ* ខាងលើដដែល ទំព័រ ១៤

(៤) ស្តេចនេះគឺជាព្រះបាទជ័យវរ្ម័នទី៧ សូមមើលសៀវភៅ *ជនជាតិខ្មែរ* ខាងលើដដែល ទំព័រ ២៨

(៥) យោងតាមសៀវភៅ *ព្រះពុទ្ធទ្រង់បង្រៀនអ្វី?* និពន្ធដោយលោក លីន កុសល បោះពុម្ពឆ្នាំ ២០១១ ទំព័រ ១៤៣-១៤៤

នៅសល់ពេលបច្ចុប្បន្ននេះ គឺខុសគ្នាឆ្ងាយណាស់! ដូចនេះ យើងអាចសន្និដ្ឋានបានថា ជីដូនជីតារបស់មនុស្សជាតិ ពីមួយជំនាន់ ទៅមួយជំនាន់ ពិតជាបានកែប្រែជំនឿ ចាស់ ជា ច្រើន លើកច្រើនសារមែន ក៏ប៉ុន្តែ ពួកគេមិនបានចាត់ទុកមាគ៌ានៃជំនឿណាមួយ ជាមាគ៌ាដ៏



ត្រឹមត្រូវនោះឡើយ។ ហេតុនេះហើយបានជាមនុស្សតែងតែកែប្រែជំនឿរបស់ខ្លួនជារៀងរហូត ពីមួយតំណទៅមួយតំណពួកគេ។ បញ្ហានេះ គួរឲ្យយើងងឿងឆ្ងល់ថា៖

*តើសាសនាមួយណា ដែលជាមាគ៌ានៃជំនាន់ដើម ហើយជាជំនឿដ៏ត្រឹមត្រូវ និងពិតប្រាកដនោះ?*

## *ភាគទី២ – មាគ៌ានៃជំនាន់ដើម*

ព្រះគម្ពីរព្រះយេស៊ូវចែងឲ្យយើងដឹងថា កាលពីដើមដំបូងបង្អស់ មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលទ្រង់ហៅថា «ព្រះដ៏មានព្រះជន្មគង់នៅ» ឬក៏ «ព្រះដ៏ជាដើមដំបូង និងជាចុងបង្អស់»។(៦) ព្រះនាមទាំងពីរនេះមានន័យថា ព្រះជាម្ចាស់ ទ្រង់គ្មានទីចាប់ផ្ដើម ឬគ្មានទីបញ្ចប់ គឺមានព្រះជន្មគង់នៅ តាំងពីមុនអស់កល្ប រហូតដល់អស់កល្បជានិច្ច ដោយសារព្រះចេស្ដារបស់ទ្រង់ផ្ទាល់។ ព្រះអង្គមិនត្រូវបានគេបង្កើត

---

(៦) យោងតាមព្រះគម្ពីរព្រះយេស៊ូវ យេរេមា ១០:១០ យ៉ូហាន ៥:២៦ និងវិវរណៈ ២១:៦

ទ្រង់មកឡើយ ហើយក៏គ្មានបុគ្គលណាម្នាក់ ដែលបានផ្តល់ជីវិតឲ្យទ្រង់មានព្រះជន្មរស់ឡើងដែរ។ ផ្ទុយទៅវិញ គឺព្រះជាម្ចាស់ទេតើ ដែលជាប្រភពនៃជីវិតទាំងឡាយ។

កាលដំបូងឡើយ ពុំទាន់មានអ្វីៗទាំងអស់ សូម្បីតែមនុស្ស ព្រលឹងវិញ្ញាណ ទេវតា ឬវត្ថុផ្សេងៗក្តី គឺមានតែព្រះជាម្ចាស់មួយព្រះអង្គប៉ុណ្ណោះ។ ដោយសារទ្រង់មានគ្រប់ព្រះចេស្តា និងឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត ទើបព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ ផែនដី និងរបស់សព្វសារពើ រួមទាំងមនុស្សដំបូងពីរនាក់ គឺលោកអ័ដាម និងនាងអេវ៉ា ជាភរិយារបស់លោក។ ពួកគេគឺជាជីដូនជីតានៃមនុស្សជាតិទាំងឡាយ។ រីឯផែនដីដែលទ្រង់បានបង្កើតមកនោះ វាល្អឥតខ្ចោះ គ្មានទុក្ខលំបាក គ្រោះកាចចង្រៃ ឬសេចក្តីស្លាប់ទាល់តែសោះ។ អ័ដាម និងអេវ៉ាក៏ល្អប្រពៃដែរ ថែមទាំងមិនចេះប្រព្រឹត្តិអំពើបាបអ្វីទៀត។ ព្រះអង្គបានប្រទានពរដល់ពួកគេ ព្រមទាំងប្រគល់អស់ទាំងធញ្ញជាតិដែលមានគ្រាប់ពូជ និងដើមឈើដែលមានផលផ្លែគ្រប់បែបយ៉ាង ទុកជាអាហារសម្រាប់ពួកគេបរិភោគតាមចិត្ត។[៧]

នៅសម័យជំនាន់ដើមនោះ ពុំមានសាសនាអ្វីទេ ក៏គ្មានរូបព្រះដែរ ពីព្រោះអ្វីៗដែលធ្វើពីឈើ ឬថ្មដែលគ្មានជីវិត ពុំអាចតំណាងឲ្យព្រះដ៏មានព្រះជន្មគង់នៅបានឡើយ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់បានបង្កើតអ័ដាម និងអេវ៉ាឲ្យធ្វើជាតំណាងព្រះអង្គផ្ទាល់ ដើម្បីបង្ហាញនូវលក្ខណៈដ៏ល្អប្រសើររបស់ទ្រង់[៨] ដូចជាកូនៗបង្ហាញនូវលក្ខណៈរបស់ឪពុកម្តាយខ្លួន។ យ៉ាងនេះដែរ អ័ដាម និងអេវ៉ាក៏មានចំណែកពិសេសវិសាលក្នុងកេរ្តិ៍ឈ្មោះរបស់ព្រះជាម្ចាស់ផ្ទាល់។

នៅសម័យជំនាន់ដើម ក៏គ្មានព្រះវិហារណាមួយត្រូវបានសាងសង់ឡើង ទុក

---

(៧) កថាខណ្ឌនេះសង្ខេបអំពីព្រះគម្ពីរព្រះយេស៊ូវ លោកុប្បត្តិ ១-២

(៨) យោងតាមព្រះគម្ពីរព្រះយេស៊ូវ លោកុប្បត្តិ ១:២៦-២៧

សម្រាប់ព្រះជាម្ចាស់គង់នៅនោះដែរ ពីព្រោះព្រះអង្គមិនចាំបាច់ពឹងពាក់ទៅលើដៃរបស់មនុស្ស ដែលទ្រង់បានបង្កើតមកនោះឡើយ។ គឺព្រះអង្គទេតើ ដែលជាអ្នកប្រទានជីវិតទាំងឡាយ និងរបស់សព្វសារពើដល់មនុស្ស ឲ្យពួកគេបានបរិភោគ និងប្រើប្រាស់តាមតំរូវការ។[៩] ដោយហេតុនេះឯងបានជា នៅសម័យជំនាន់ដើម មនុស្សមិនចាំបាច់បួងសួង ឬធ្វើពិធីផ្សេងៗ ដើម្បីសុំអ្វីមួយពីព្រះជាម្ចាស់នោះឡើយ ពីព្រោះទ្រង់បានប្រទានអ្វីៗគ្រប់យ៉ាងមកដល់ពួកគេហើយ។ ដូចនេះ អ័ដាម និងអេវ៉ាបានប្រកបជាមួយព្រះជាម្ចាស់ផ្ទាល់ ទាំងពឹងលើទ្រង់គ្រប់ជំពូក ដូចជាកូនប្រកបជាមួយឪពុកម្ដាយដោយសុភមង្គលបំផុត។

## *ភាគទី៣ – មនុស្សបានបះបោរប្រឆាំងជំទាស់នឹងព្រះជាម្ចាស់*

ប៉ុន្តែ នៅថ្ងៃមួយ អ័ដាម និងអេវ៉ាបានបះបោរប្រឆាំងទៅនឹងព្រះជាម្ចាស់ ដោយពួកគេពុំបានស្ដាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ តែបែរជាពឹងលើគំនិតរបស់ខ្លួនទៅវិញ។ ពួកគេស្មានថា នឹងបានលើកខ្លួនជាធំស្មើនឹងឋានៈព្រះអង្គ និងក្លាយជាម្ចាស់



លើខ្លួនឯង ផ្ទុយទៅវិញបានតែធ្វើឲ្យខ្លួនអាក្រក់តែប៉ុណ្ណោះ។[១០] ការនេះប្រៀបបានដូចជាកូនប្រុសរបស់មន្ត្រីមានកេរ្តិ៍ឈ្មោះល្អម្នាក់ ដែលមិនបានស្ដាប់

(៩) យោងតាមព្រះគម្ពីរព្រះយេស៊ូវ កិច្ចការ ១៧:២៤-២៥

(១០) កថាខណ្ឌនេះសង្ខេបអំពីព្រះគម្ពីរព្រះយេស៊ូវ លោកុប្បត្តិ ៣

ដំបូន្មានរបស់ឪពុកម្ដាយ តែវាបែរជាក្លាយជាក្មេងទំនើង ដើរអុកឡុកពេញភូមិ។ លទ្ធផលចុងក្រោយ គឺវាបានបង្ខូចកេរ្តិ៍ឈ្មោះរបស់ឪពុក ធ្វើឲ្យលោកខ្មាសគេយ៉ាងខ្លាំង នៅចំពោះមុខមនុស្សគ្រប់ៗរូប រួមទាំងនាំឲ្យគេប្រមាថមាក់ងាយដល់ខ្លួនថែមទៀតផង! ដូចគ្នានេះ អ័ដាម និងអេវ៉ាបានបង្អាប់បង្អោនដល់ព្រះកិត្តិនាមដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដោយព្រោះព្រះអង្គបានបង្កើតពួកគេមកតាមលក្ខណៈដ៏ល្អប្រសើររបស់ទ្រង់ផ្ទាល់ ប៉ុន្តែ ពួកគេបានបែរជាធ្វើឲ្យខ្លួនអាក្រក់ទៅវិញ។

ម្ល៉ោះហើយ ទើបព្រះជាម្ចាស់បានដាក់បណ្ដាសាដល់ផែនដី នាំឲ្យមានទុក្ខលំបាក និងសេចក្ដីស្លាប់ចូលមកក្នុងលោកីយ៍ជាលើកដំបូង។ នេះជាទណ្ឌកម្មសមហេតុសមផល ដែលគេត្រូវទទួលយក ដោយសារអំពើអាក្រក់របស់ពួកគេ។[១១] លុះក្រោយមក ពូជពង្សរបស់អ័ដាម និងអេវ៉ាបាននាំគ្នាប្រព្រឹត្តិអំពើបាប ប្រឆាំងទៅនឹងព្រះអង្គកាន់តែខ្លាំងឡើងៗ ទើបព្រះជាម្ចាស់ក៏បានបំភាន់ភាសារបស់ពួកគេ មិនឲ្យស្ដាប់គ្នាបាន។ ការនេះធ្វើឲ្យមនុស្សជាតិបានបែកខ្ញែកគ្នា ទៅជាជាតិសាសន៍ដទៃតាមពូជអំបូររៀងៗខ្លួន ព្រមទាំងទៅរស់នៅក្នុងតំបន់ និងនិយាយភាសាផ្សេងៗពីគ្នា ចាប់តាំងពីពេលនោះមក។[១២]



(១១) យោងតាមព្រះគម្ពីរព្រះយេស៊ូវ លោកុប្បត្តិ ៣:១៧-១៩

(១២) កថាខណ្ឌនេះសង្ខេបអំពីព្រះគម្ពីរព្រះយេស៊ូវ លោកុប្បត្តិ ១១:១-៩

# *ភាគទី៤ – មនុស្សបានបង្កើតជំនឿ និងសាសនា ដើម្បីមានទីពឹងជំនួសព្រះជាម្ចាស់*

ពីមួយជំនាន់ ទៅមួយជំនាន់ មនុស្សជាតិបានភ្លេចព្រះដែលបានបង្កើតខ្លួនបន្តិចម្តងៗ រហូតដល់បំភ្លេចទ្រង់ទាំងស្រុង។ ប៉ុន្តែ បណ្តាសា ការរងទុក្ខលំបាក និងសេចក្តីស្លាប់ នៅតែមាននៅលើផែនដីដដែល។ ដូច្នេះហើយ ទើបមនុស្សគិតឃើញថាត្រូវការរកទីពឹងណាដែលធំ និងខ្លាំងពូកែជាងខ្លួន ដើម្បីមានទីកក្តៀងធ្វើស្រែចំការ និងជួយបណ្តេញគ្រោះកាចចង្រៃ ឲ្យបានរស់រានមានជីវិតបន្តទៅមុខទៀត។

ដូច្នេះ ដោយសារការនឹកឃើញតាមចិត្តរបស់ខ្លួន មនុស្សបានយកដុំថ្ម ឈើ ប្រាក់ មាស មកច្នៃឲ្យមានរូបសណ្ឋានផ្សេងៗ ដូចអ្វីដែលព្រះជាម្ចាស់បានបង្កើតមក ដូចជាសត្វ ឬមនុស្សជាដើម។ រួចមក ពួកគេបាននាំគ្នាក្រាបចុះថ្វាយបង្គំរូបទាំងនោះ ដោយចាត់ទុកវាជាព្រះរបស់ខ្លួនជំនួសព្រះជាម្ចាស់ទៅវិញ។ មនុស្សក៏បានគោរពព្រលឹងវិញ្ញាណរបស់ជីដូនជីតាដែលបានស្លាប់ទៅ ដោយចាត់ទុកពួកគេជាព្រះរបស់ខ្លួនថែមទៀត។ មនុស្សបានគោរពថ្វាយបង្គំវត្ថុទាំងនោះ តាមពិធីដែលខ្លួនបានច្នៃប្រឌិត និងបង្កើតមក ដែលហៅថា «សាសនា» ដោយសង្ឃឹមថា វានឹងអាចជួយ



*ជនជាតិ កាណាន បុរាណកំពុងតែឆ្លាក់រូបព្រះម៉ូឡុក ប្រមាណឆ្នាំ ១.៥០០ មុនគ្រិស្តសករាជ*



*ជនជាតិ អាម៉ូរី បុរាណសែនព្រេនដូនតា ក្នុងផ្ទះរបស់ខ្លួន ប្រមាណឆ្នាំ ២.០០០ មុនគ្រិស្តសករាជ*



*ជនជាតិ អេហ្ស៊ីប បុរាណថ្វាយបង្គំរូបព្រះរ៉ា ក្នុងវិហា ប្រមាណឆ្នាំ ២.៥០០ មុនគ្រិស្តសករាជ*



រំដោះពួកគេឲ្យរួចពីការរងទុក្ខលំបាក គ្រោះកាចចង្រៃ ឬសេចក្ដីស្លាប់បាន។ ប៉ុន្តែ ការបន់ស្រន់ បួងសួងបែបនេះ វាមិនអាចរំដោះពួកគេឲ្យរួចផុតពីបណ្ដាសា ដែលព្រះជាម្ចាស់បានដាក់ទៅលើផែនដីនោះទាល់តែសោះ។ ផ្ទុយទៅវិញ ទង្វើបែបនេះ វាបានតែប្រឆាំងជំទាស់ទៅនឹងព្រះអង្គកាន់តែខ្លាំងឡើងៗទៅវិញទេ។(១៣)

ទោះបីជាមនុស្សបានប្រព្រឹត្តិបែបនេះក៏ដោយ ក៏ព្រះជាម្ចាស់នៅតែបន្តប្រទានទឹកភ្លៀងគ្រប់គ្រាន់ដើម្បីធ្វើស្រែចំការ ទុកឲ្យពួកគេនៅមានជីវិតស្ថិតស្ថេរគង់វង្ស(១៤) ពីព្រោះព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដល់មនុស្សជាតិ ដែលទ្រង់បានបង្កើតមក។ ប៉ុន្តែ ពួកគេបែរជាលើកតម្កើង ហើយថ្លែងអំណរគុណដល់រូបព្រះក្លែងក្លាយដែលខ្លួនបានឆ្លាក់ពីថ្ម ឬឈើទៅវិញ ដោយស្មានថា វត្ថុទាំងនោះបានធ្វើឲ្យមានទឹកភ្លៀងធ្លាក់មកចិញ្ចឹមជីវិតរបស់ពួកគេ។ ទង្វើនេះធ្វើឲ្យព្រះជាម្ចាស់ ជាព្រះដ៏ពិត កើតមានព្រះហឫទ័យក្រេវក្រោធជាខ្លាំង!(១៥)

យ៉ាងណាមិញ យើងឃើញថា មនុស្សបានធ្វើខ្លួនទៅជាល្ងីល្ងើ ដោយបំភ្លេចព្រះដ៏មានព្រះជន្មគង់នៅចោល ហើយបែរជាផ្ញើជីវិតរបស់ខ្លួនដែលបានពីព្រះជាម្ចាស់មក ទៅលើវត្ថុដែលគ្មានជីវិតទៅវិញ។ ហេតុនេះហើយបានជាព្រះជាម្ចាស់ ទ្រង់បណ្ដោយឲ្យពួកគេប្រព្រឹត្តិតាមអំពើចិត្តលោភលន់របស់ខ្លួន គឺគេបានបន្ទាបបន្ថោក

(១៣) យោងតាមព្រះគម្ពីរព្រះយេស៊ូវ ចោទិយកថា ២៧:១៥៖ « **ត្រូវបណ្ដាសាហើយ អ្នកណាដែលឆ្លាក់ ឬសិតធ្វើរូប ដែលជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់ គឺជារបស់ដែលជាងធ្វើ** »។

(១៤) យោងតាមព្រះគម្ពីរព្រះយេស៊ូវ ម៉ាថាយ ៥:៤៥

(១៥) យោងតាមព្រះគម្ពីរព្រះយេស៊ូវ រ៉ូម ១:១៨-២១

ដល់ខ្លួនឯង ដោយប្រព្រឹត្តិអំពើសៅហ្មងគ្រប់បែបយ៉ាង ដូចជាអំពើផិតក្បត់ សហាយស្មន់ ចង់សម្លាប់គេ លួចប្លន់ អំនួតអួតអាង ខិលខូច ឧបាយកល អាសអាភាស ច្រណែនឈ្នានីស ជេរប្រមាថ ឥតស្តាប់បង្គាប់ឪពុកម្តាយ ប្រមឹកស៊ីផឹក ជ្រុល និងអំពើផ្សេងៗទៀត ដែលស្រដៀងទៅនឹងអំពើទាំងនេះផងដែរ។ ទង្វើទាំងនេះ



ជាភស្តុតាងបង្ហាញថា មនុស្សជាតិបានធ្វើខ្លួនឲ្យត្រឡប់ជាអាក្រក់ហួសល្បត់។ នៅក្នុងចិត្តរបស់ខ្លួន មនុស្សយើងដឹងហើយថា អ្នកណាដែលប្រព្រឹត្តិបែបនេះ គួរនឹងទទួលទោសដល់ជីវិត។[១៦] ហេតុនេះហើយបានជាមនុស្សខំប្រឹងធ្វើល្អវិញ ប៉ុន្តែ ធ្វើបានតែមួយភ្លែតៗប៉ុណ្ណោះ រួចបែរទៅប្រព្រឹត្តិអំពើបាបវិញទៀត ពីព្រោះមនុស្សជាតិទាំងឡាយកំពុងតែជាប់មាននិស្ស័យបាបនៅនឹងខ្លួន ដែលយើងមិនអាចកែតម្រូវឲ្យល្អដូចដើមវិញបានឡើយ។

រីឯសាសនាទាំងប៉ុន្មានដែលមនុស្សបង្កើតមក វាមិនដែលបានរំដោះយើងពីបណ្តាសា ដែលព្រះជាម្ចាស់បានដាក់ទៅលើផែនដីនោះឡើយ។ ហេតុនេះហើយបានជាមនុស្សតែងតែកែប្រែជំនឿរបស់ខ្លួន ពីមួយជំនាន់ ទៅមួយជំនាន់ ដើម្បីរកបានដំណោះស្រាយណាមួយដែលពិតប្រាកដត្រឹមត្រូវ តែពួកគេនៅតែរកមិនបានសោះ។ លើសពីនេះទៅទៀត សាសនាទាំងប៉ុន្មាន ដែលមនុស្សបង្កើតមកនោះ ក៏មិនមែនជាមាគ៌ានៃជំនឿដ៏ពិតដែរ។ តាមមាគ៌ានៃជំនឿដ៏ពិត គឺព្រះជាម្ចាស់បានបង្កើតមនុស្សដែលទាបជាងទ្រង់មក ដោយព្រះចេស្តាដ៏ខ្លាំងពូកែបំផុតរបស់ទ្រង់ផ្ទាល់។ ព្រះអង្គបានធ្វើឲ្យពួកគេមានតំរូវការ ដើម្បីឲ្យមនុស្សចេះស្វែងរកព្រះជាម្ចាស់ យកទ្រង់ជា

(១៦) កថាខណ្ឌនេះសង្ខេបអំពីព្រះគម្ពីរព្រះយេស៊ូវ រ៉ូម ១:២២-៣២

ទីពឹងសម្រាប់ខ្លួនជានិច្ច។ ក៏ប៉ុន្តែ តាមគំនិតល្ងីល្ងើរបស់មនុស្ស នៅពេលដែលពួកគេកំពុងតែស្ថិតក្នុងភាពទន់ខ្សោយ ហើយត្រូវការរកទីពឹង ពួកគេគិតថា ខ្លួនមានសមត្ថភាពអាចបង្កើតព្រះមួយដែលខ្លាំងពូកែជាងខ្លួនបាន ដើម្បីយកព្រះនោះធ្វើជាទីពឹងអាងទៅវិញ! កូនមិនអាចបង្កើតឪពុកម្តាយរបស់ខ្លួន ដើម្បីយកធ្វើជាទីពឹងក្នុងជីវិតបានទេ។ ដូចគ្នានេះដែរ មនុស្សក៏រឹតតែមិនអាចបង្កើតព្រះ ដែលធំជាងខ្លួន ដើម្បីយកធ្វើជាទីពឹងអាងបានឡើយ។ សូមលោកអ្នកយកចំណុចដ៏សំខាន់នេះមករិះគិតពិចារណាចុះ៖

*មនុស្សត្រូវការពឹងផ្អែកទៅលើព្រះអាទិករ ដែលបានបង្កបង្កើតខ្លួនមក តើមនុស្សអាចពឹងផ្អែកទៅលើព្រះណា ដែលខ្លួនបានបង្កើតបានដែរឬទេ?*

យើងឃើញថា រហូតមកទល់សព្វថ្ងៃនេះ មនុស្សជាតិទាំងឡាយប្រៀបបានដូចជាមនុស្សខ្វាក់ភ្នែក ដែលបានវង្វេងឆ្ងាយពីមាគ៌ាដ៏ល្អ ចូលទៅក្នុងព្រៃខ្មោច ទើបគេនាំគ្នារាវពីមពើម រកដានណាដែលអាចនាំគេឲ្យរួចពីព្រៃបាន។ តែផ្ទុយទៅវិញ គេត្រូវបានឃ្លាតពីមាគ៌ាដ៏ល្អ ចូលក្នុងព្រៃកាន់តែជ្រៅទៅៗ ហើយភ័យញ័ររន្ធត់ជានិច្ច។ តើអ្នកណាអាចសង្គ្រោះគេបាន?



# *ភាគទី៥ – ព្រះជាម្ចាស់បានរៀបចំផែនការសង្គ្រោះមនុស្ស*

ទាល់តែមានអ្នកដែលមើលឃើញ ហើយស្គាល់ព្រៃ និងផ្លូវច្បាស់ ទើបអាចដឹកដែនាំផ្លូវពួកគេ ឲ្យរួចពីការវង្វេងនៅក្នុងព្រៃនេះ ទៅរកមាគ៌ាដ៏ត្រឹមត្រូវវិញបាន។ មានតែព្រះជាម្ចាស់មួយព្រះអង្គប៉ុណ្ណោះ ដែលអាចធ្វើការនេះបាន។ ព្រះអង្គនៅតែមានព្រះហឫទ័យមេត្តាករុណា អាណិតអាសូរដល់មនុស្សដែលទ្រង់បានបង្កើតមក ប្រៀបបានដូចជាឪពុកល្អតែងឈឺឆ្អាលដល់កូនរបស់ខ្លួនដែលកើតរោគកាច ស្ទើរផុតដង្ហើមដែរ គឺលោកចង់សង្គ្រោះកូនណាស់! ហេតុនេះហើយបានជាព្រះជាម្ចាស់បានសំរេចព្រះហឫទ័យរៀបចំផែនការមួយ ដោយចាត់ព្រះរាជបុត្រាព្រះអង្គផ្ទាល់ ចូលទៅក្នុងព្រៃដឹកដៃមនុស្ស ឲ្យបានត្រឡប់មកឯមាគ៌ាដើមវិញ។

នៅនាឆ្នាំប្រមាណ ៧០០ មុនគ្រិស្តសករាជ (១៥៧ ឆ្នាំមុនពុទ្ធសករាជ) ព្រះជាម្ចាស់បានត្រាស់ហៅបុរសម្នាក់ឈ្មោះអេសាយ រួចហើយព្រះអង្គក៏មានព្រះបន្ទូលជាច្រើនតាមរយៈលោក ប្រកាសអំពីផែនការរបស់ទ្រង់។ លោកអេសាយបានប្រាប់ឲ្យគេដឹងថា ព្រះជាម្ចាស់ ទ្រង់នឹងចាត់ព្រះសង្គ្រោះមួយអង្គយាងមកសង្គ្រោះមនុស្សឲ្យរួចពីបាប។ លោកពោលថា៖ « **ព្រះអម្ចាស់ ទ្រង់នឹងប្រទានទីសំគាល់មួយមកអ្នករាល់គ្នាដោយព្រះអង្គទ្រង់ មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយនិងឲ្យព្រះនាមថា “អេម៉ាញូអែល”** » ប្រែថា « ព្រះជាម្ចាស់គង់ជាមួយយើង »។(១៧) លោកអេសាយប្រាប់ឲ្យគេដឹងថា នឹងមានឮសំឡេងមួយស្រែកនៅវាលរហោស្ថានថា « **ចូររៀបចំផ្លូវសម្រាប់ទទួលព្រះអង្គ** »។(១៨)

---

(១៧) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ អេសាយ ៧:១៤

(១៨) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ អេសាយ ៤០:៣

ព្រះជាម្ចាស់ក៏បានរំលឹកពួកគេជាច្រើនដងតាមរយៈលោកអេសាយ អំពីព្រះដ៏ពិតតែមួយព្រះអង្គនោះថា ទ្រង់ជានរណា ព្រមទាំងពន្យល់ពួកគេថា ការថ្វាយបង្គំអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក ជំនួសព្រះអង្គផ្ទាល់ នោះមិនត្រឹមត្រូវឡើយ។ លោកអេសាយបានលើកឡើងថា គេកាប់ដើមឈើដ៏ធំៗ ដែលដុះលូតលាស់ឡើងដោយសារទឹកភ្លៀងដែលព្រះជាម្ចាស់ប្រទានមក គេក៏យកមួយចំណែកមកពុះជាអុសចំអិនម្ហូប តែខ្លឹមឈើដែលមានតម្លៃជាង គេយកមកឆ្លាក់ធ្វើរូបបដិមា រួចក៏ក្រាបទូលអង្វរដល់រូបនោះថា៖ «សូមជួយរំដោះទូលបង្គំផង! ដ្បិតព្រះអង្គជាព្រះរបស់ទូលបង្គំ!»។ លោកប្រាប់គេថា ភ្នែកគេងងឹតមើលអ្វីពុំឃើញ ហើយចិត្តគេក៏ពុំយល់អ្វីដែរ គ្មាននរណាម្នាក់ចាប់អារម្មណ៍ រិះគិតពិចារណាថា៖ «ខ្ញុំបានដុតឈើនេះ អស់ពាក់កណ្ដាលដាំបាយហូបឆ្អែត រីឯឈើពាក់កណ្ដាលនៅសល់ ខ្ញុំយកទៅធ្វើជារូបព្រះ រួចខ្ញុំនឹងក្រាបថ្វាយបង្គំដុំឈើនោះ!»។(១៩)





ឮអញ្ចឹង មនុស្សមុខជាខឹងលោកណាស់ ពីព្រោះហាក់ដូចជាលោកមានបំណង ចង់មើលងាយគេ តែផ្ទុយទៅវិញ លោកមានចិត្តឈឺឆ្អាល ចង់នាំឲ្យគេភ្ញាក់ដឹងខ្លួន កែប្រែចិត្តគំនិត លើកតម្កើងសិរីរុងរឿងនៃព្រះដ៏ពិតតែមួយព្រះអង្គវិញ។

៧០០ ឆ្នាំកន្លងផុតទៅ នៅនាដើមសម័យព្រះយេស៊ូវ ព្រះជាម្ចាស់បានចាត់បុរសម្នាក់ទៀតឲ្យមក ដើម្បីរៀបចំផ្លូវសម្រាប់ទទួលព្រះអង្គសង្គ្រោះ តាមពាក្យទំនាយ

(១៩) កថាខណ្ឌនេះសង្ខេបអំពីព្រះគម្ពីរព្រះយេស៊ូវ អេសាយ ៤៤:៩-២០

របស់លោកអេសាយ។ បុរសនេះឈ្មោះយ៉ូហាន ប្រែថា «ព្រះជាម្ចាស់បានផ្ដល់ព្រះគុណ»។ លោកយ៉ូហានរស់នៅក្នុងវាលរហោស្ថាន ហើយឧស្សាហ៍ប្រាប់មនុស្សឲ្យកែប្រែចិត្តគំនិតជាថ្មី ដើម្បីឲ្យព្រះជាម្ចាស់លើកលែងទោសឲ្យរួចពីបាប ពីព្រោះនៅថ្ងៃមួយ ព្រះអង្គនឹងជំនុំជំរះគេដោយភ្លើង។[២០] មនុស្សខ្លះគិតថា ប្រហែលជាអ្នកនេះជាអ្នកសង្គ្រោះដែលត្រូវយាងមក តាមដែលមានចែងទុកក្នុងព្រះគម្ពីរ តែលោកយ៉ូហានប្រកែកថា៖ «**មិនមែនទេ ខ្ញុំជាសំឡេង ដែលបន្លឺឡើងនៅទីរហោស្ថានថា "ចូរតំរង់ផ្លូវថ្វាយព្រះអម្ចាស់" ដូចជាលោកអេសាយបានទាយទុក**»។[២១] លោកយ៉ូហានពោលទៀតថា៖ «**ព្រះអង្គដែលយាងមកក្រោយខ្ញុំ ទ្រង់មានអំណាចលើសជាងខ្ញុំទៅទៀត!**»។[២២]

## *ភាគទី៦ – តើព្រះយេស៊ូវ ទ្រង់ជានរណា?*

លុះដល់ពេលកំណត់ហើយ ព្រះជាម្ចាស់ក៏ចាត់ព្រះអង្គសង្គ្រោះឲ្យយាងចូលមកក្នុងលោកីយ៍ ប្រសូតចេញពីស្ត្រីព្រហ្មចារីម្នាក់។ នេះជាទីសំគាល់ដែលព្រះជាម្ចាស់បានមានព្រះបន្ទូលទាយ តាមរយៈលោកអេសាយ ៧០០ ឆ្នាំមុន បញ្ជាក់ថា បុត្រនេះជាព្រះរាជបុត្រានៃព្រះជាម្ចាស់ ដែលត្រូវយាងមកពិតមែន។ ទេវតារបស់ព្រះជាម្ចាស់ក៏បានបង្គាប់ឲ្យគេថ្វាយព្រះនាមថា «យេស៊ូវ» ដែលមានន័យថា «ព្រះជាម្ចាស់ជាទីសង្គ្រោះ»។[២៣]

*ព្រះនាម «យេស៊ូវ» ប្រែថា «ព្រះជាម្ចាស់ជាទីសង្គ្រោះ»*

---

(២០) កថាខណ្ឌនេះសង្ខេបអំពីព្រះគម្ពីរព្រះយេស៊ូវ ម៉ាថាយ ៣:១-១២ និងម៉ាកុស ១:២-៤

(២១) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ១:២៣

(២២) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ ម៉ាកុស ១:៧

(២៣) យោងតាមព្រះគម្ពីរព្រះយេស៊ូវ ម៉ាថាយ ១:២១ និងលូកា ១:៣១

នៅថ្ងៃមួយ លោកយ៉ូហានឃើញព្រះយេស៊ូវយាងមករកលោក លោកក៏មានប្រសាសន៍ប្រាប់គេថា ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះនៃព្រះជាម្ចាស់ ដែលដកបាបចេញពីមនុស្សលោក។ លោកពោលបន្តថា៖ « **គឺពីព្រះអង្គនេះហើយ ដែលខ្ញុំប្រាប់ថា ព្រះអង្គដែលយាងមកក្រោយខ្ញុំ ទ្រង់មានឋានៈប្រសើរជាងខ្ញុំ ដ្បិតទ្រង់គង់នៅមុនខ្ញុំ** »។[២៤] គួរឲ្យកត់សំគាល់ ដែលគាត់មានប្រសាសន៍ថា៖ « **ទ្រង់គង់នៅមុនខ្ញុំ** » ពីព្រោះខាងសាច់ឈាម លោកយ៉ូហានមានអាយុច្រើនជាងព្រះយេស៊ូវ ៦ ខែ ក៏ប៉ុន្តែ កុំឲ្យយល់ច្រឡំ គាត់បានពោលបែបនេះ មកពីគាត់ដឹងច្បាស់ថា ព្រះយេស៊ូវមានព្រះជន្មគង់នៅតាំងពីមុនអស់កល្ប គឺមុនពេលមានអ្វីៗទាំងអស់ ហើយប្រហែលជាពីរពាន់ឆ្នាំមុនសម័យបច្ចុប្បន្ននេះ ទើបព្រះយេស៊ូវបានប្រសូតជាមនុស្សមានសាច់ឈាម។[២៥]

*ព្រះយេស៊ូវមានព្រះជន្មគង់នៅតាំងពីមុនកំណើតលោកីយ៍ និងរបស់សព្វសារពើទាំងអស់*

នៅពេលមួយដែលព្រះយេស៊ូវនៅជាមួយនឹងលោកយ៉ូហាន ស្រាប់តែមានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ពីលើមេឃមកថា៖ « **ឯងជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់!** » នោះលោកយ៉ូហានបានផ្តល់សក្ខីភាពអំពីព្រះយេស៊ូវថា៖ « **ទ្រង់ជាព្រះរាជបុត្រានៃព្រះពិតមែន!** »។[២៦]

ព្រះយេស៊ូវបានត្រាស់ហៅមនុស្សឲ្យកែប្រែចិត្តគំនិត ដូចជាលោកអេសាយ និងលោកយ៉ូហានដែរ ទ្រង់ក៏មានព្រះបន្ទូលជាច្រើន ព្រមានពួកគេអំពីថ្ងៃជំនុំជំរះនៃព្រះជាម្ចាស់ដែលត្រូវមកដល់។ ដោយសារព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះជាម្ចាស់ផ្ទាល់ ទើបទ្រង់អាចធ្វើជាអ្នកតំណាងឲ្យព្រះដ៏ពិតប្រាកដ ផ្សះផ្សាយើងឲ្យស្គាល់ទ្រង់

(២៤) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ១:២៩-៣០

(២៥) យោងតាមព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ១:១-២ និង ១៤

(២៦) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ ម៉ាកុស ១:១១ និងយ៉ូហាន ១:៣៤

ឡើងវិញបាន ។[២៧] ព្រះយេស៊ូវមានព្រះបន្ទូលប្រាប់គេថា ៖ « **ព្រះអង្គដែលចាត់ឲ្យខ្ញុំមក ទ្រង់ពិតប្រាកដ ហើយសេចក្ដីអ្វីដែលខ្ញុំបានឮពីទ្រង់ នោះខ្ញុំក៏ប្រាប់ដល់មនុស្សលោកដែរ** » ។[២៨] ព្រះយេស៊ូវក៏មានព្រះបន្ទូលដែរថា ៖ « **ខ្ញុំ ហើយនិងព្រះវរបិតា គឺតែមួយព្រះអង្គទេ** » ។[២៩] ដូច្នេះហើយ ទើបព្រះយេស៊ូវជារស្មីនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ផ្ទាល់ និងជាពន្លឺដ៏ពិតប្រាកដតែមួយប៉ុណ្ណោះ ដែលមកក្នុងលោកីយ៍ អាចបំភ្លឺមនុស្សទាំងឡាយបាន ។[៣០] ហេតុនេះហើយបានជាព្រះយេស៊ូវមានព្រះបន្ទូលថា ៖ « **ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ** » ។[៣១]

*ព្រះយេស៊ូវជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត*

## *ភាគទី៧ – មនុស្សទាំងអស់នឹងត្រឡប់ទៅឯមាគ៌ាដើមវិញ*

ដោយសារព្រះជាម្ចាស់បានបង្កើតលោកីយ៍ទាំងមូល និងមនុស្សជាតិទាំងឡាយ ទើបព្រះអង្គមានសិទ្ធិអំណាចជំនុំជំរះមនុស្សគ្រប់ៗរូប គ្មាននរណាម្នាក់អាចគេចផុតពីការជំនុំជំរះរបស់ព្រះជាម្ចាស់បានឡើយ ។ ព្រះជាម្ចាស់ ទ្រង់នឹងវិនិច្ឆ័យលោកីយ៍ទាំងមូលដោយយុត្តិធម៌ ទៅតាមអស់ទាំងគំនិតដែលមានក្នុងចិត្តរបស់មនុស្ស និងទង្វើទាំងប៉ុន្មានដែលពួកគេបានប្រព្រឹត្តិ ។ ដោយព្រោះព្រះជាម្ចាស់ ទ្រង់ជា « ព្រះដ៏ជាដើមដំបូង និងជាចុងបង្អស់ » នៅថ្ងៃនោះ មនុស្សគ្រប់ៗគ្នានឹងត្រឡប់មក

(២៧) យោងតាមព្រះគម្ពីរព្រះយេស៊ូវ កូឡុស ១:១៥

(២៨) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ៨:២៦

(២៩) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ១០:៣០

(៣០) យោងតាមព្រះគម្ពីរព្រះយេស៊ូវ ហេព្រើរ ១:៣ ហើយនិងយ៉ូហាន ១:៤ និង ៨:១២

(៣១) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ១៤:៦

ឯមាគ៌ាដើមវិញជាមិនខាន ទោះជាគេមិនព្រមក៏ដោយ។ សាវ័កនៃព្រះយេស៊ូវមួយរូបបានពោលថា គ្រប់ទាំងជង្គង់នឹងលុតក្រាបចុះ ហើយមនុស្សគ្រប់ភាសានឹងថ្វាយសិរីរុងរឿងទូលដល់ព្រះជាម្ចាស់ ដោយថ្លែងប្រកាសឡើងថា៖ « **ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាព្រះអម្ចាស់!** »។[៣២]

***យើងមិនអាចគេចផុតពីសេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់បានឡើយ***

ចំពោះអស់អ្នកណាដែលទទួលជឿលើព្រះយេស៊ូវ កែប្រែចិត្តគំនិត បែរមកគោរពប្រតិបត្តិតាមព្រះដ៏ពិតតែមួយវិញ ព្រះជាម្ចាស់នឹងសង្គ្រោះគេឲ្យរួចពីទណ្ឌកម្មនៅថ្ងៃជំនុំជំរះនោះ។ ព្រះអង្គក៏នឹងប្រទានឲ្យពួកគេ អាចទៅជាបុត្ររបស់ទ្រង់ផ្ទាល់ រួមទាំងប្រទានជីវិតអមតៈឲ្យពួកគេបានរស់នៅលើផែនដីថ្មី ដែលទ្រង់នឹងបង្កើតផងដែរ។[៣៣] មានសេចក្តីចែងទុកក្នុងព្រះគម្ពីរព្រះយេស៊ូវថា៖ « **ព្រះ ទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ នឹងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ** »[៣៤] ពីព្រោះនៅលើផែនដីថ្មីនោះ នឹងលែងមានបាប ឬបណ្តាសាទៀតហើយ។ នោះពួកគេនឹងប្រកបដោយសិរីរុងរឿង និងសុភមង្គលបំផុត ជាមួយនឹងព្រះជាម្ចាស់ និងព្រះគ្រីស្ទយេស៊ូវ រហូតដល់អស់កល្បតរៀងទៅ។

រីឯអស់អ្នកណាដែលបដិសេធមិនព្រមទទួលស្គាល់ព្រះយេស៊ូវ នោះទ្រង់ក៏នឹងបដិសេធមិនព្រមទទួលស្គាល់គេវិញដែរ។ ពួកគេប្រាកដជានឹងបានទៅដល់ទីដៅរបស់ផ្លូវ ដែលខ្លួនបានដើរជាមិនខាន គឺនៅថ្ងៃជំនុំជំរះនោះ ពួកគេនឹងនាំគ្នារត់ពួនដើម្បីគេចឲ្យផុតពីសេចក្តីក្រេវក្រោធរបស់ព្រះជាម្ចាស់។ ពួកគេនឹងបោះបង់អស់ទាំងរូបព្រះក្លែងក្លាយ ដែលបានធ្វើពីឈើ ឬថ្មចោល ពីព្រោះវាមិនមានប្រយោជន៍អ្វីសោះ

(៣២) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ ភីលីព ២:១០-១១

(៣៣) យោងតាមព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ១:១២ និង ៣:៣៦ ហើយនិងវិវរណៈ ២១:១

(៣៤) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ វិវរណៈ ២១:៤

អាចនឹងជួយគេ ឲ្យរួចផុតពីសេចក្តីក្រេវក្រោធរបស់ព្រះដ៏មានព្រះចេស្តាខ្ពង់ខ្ពស់បំផុតនៅថ្ងៃនោះបានឡើយ ។[៣៥] មិនថាធ្វើអ្វីក៏ដោយ ពួកគេមុខតែនឹងត្រូវបានបោះបង់ចោលទៅក្នុងឋាននរក ដែលព្រះគម្ពីរហៅថា « បឹងភ្លើង » ដែលមិនចេះរលត់ ហើយ



ផ្សែងភ្លើងវានឹងហុយឡើងដល់អស់កល្បជានិច្ច ។[៣៦] ពួកគេនឹងនៅទីងងឹតអន្ធការដ៏មហាវេទនាបែបនេះជារៀងរហូត ពីព្រោះបានធ្វើឲ្យខ្លួនគំរក់ចោលម្សៀតចំពោះព្រះជាម្ចាស់ ដោយបានប្រព្រឹត្តិអំពើសៅហ្មង ជាពិសេសពួកគេបានប្រមាថមាក់ងាយដល់ព្រះកិត្តិនាមដ៏វិសុទ្ធនៃព្រះអង្គ ថែមទាំងព្រះគុណដ៏លើសលប់របស់ទ្រង់ ដែលជួយសង្គ្រោះពួកគេទៀតផង! ពួកគេនឹងលែងឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់ ពន្លឺ ឬអ្វីៗល្អទៀត រហូតដល់អស់កល្បជាអង្វែងតរៀងទៅ ។[៣៧]

ក្នុងព្រះគម្ពីរមានចែងទុកមកថា ៖ « **ឯអ្នកណាដែលជឿដល់ព្រះយេស៊ូវ នោះមិនជាប់មានទោសទេ តែអ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយ ពីព្រោះមិនបានជឿដល់ព្រះនាមនៃព្រះរាជបុត្រាតែមួយរបស់ព្រះ ហើយទោសនេះ គឺថា ពន្លឺបានមកក្នុងលោកីយ៍ តែមនុស្សលោកចូលចិត្តនឹងសេចក្តីងងឹតជាជាងពន្លឺ** » ។[៣៨]

(៣៥) យោងតាមព្រះគម្ពីរព្រះយេស៊ូវ អេសាយ ២:១២-២១

(៣៦) យោងតាមព្រះគម្ពីរព្រះយេស៊ូវ ម៉ាកុស ៩:៤៣-៤៨ ហើយនិងវិវរណៈ ១៤:១១ និង ២០:១៤

(៣៧) យោងតាមព្រះគម្ពីរព្រះយេស៊ូវ ថែស្សាឡូនីចទី២ ១:៨-១០ យូដាស ១:១៣ និងវិវរណៈ ២១:៨

(៣៨) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យ៉ូហាន ៣:១៨-១៩

# *ភាគទី៨ – តើលោកអ្នកកំពុងដើរតាមមាគ៌ាមួយណា?*



ព្រះ យេស៊ូវ មាន ព្រះ បន្ទូល ថា ៖ « ចូរឲ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅឯសេចក្ដីហិនវិនាស នោះធំ ហើយទូលាយផង ក៏មានមនុស្សជាច្រើន ដែលចូលតាមទ្វារនោះ តែឯទ្វារដែលនាំទៅឯជីវិតនោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ ដែលរកផ្លូវនោះឃើញ » ។[៣៩]

តើលោកអ្នកកំពុងដើរតាមមាគ៌ាមួយណា? តើនរណាបានរៀបចំមាគ៌ានោះឲ្យ? តើមាគ៌ានោះនឹងនាំលោកអ្នកឲ្យបានទៅដល់ទីណា? នៅថ្ងៃជំនុំជំរះ តើលោកអ្នកគិតស្មានថា នឹងបានទទួលអ្វីពីព្រះជាម្ចាស់ដែរ? ទ្រង់មានព្រះបន្ទូលថា ៖

**« ចូរឈប់មួយសន្ទុះ ហើយពិចារណាមើល៍**
**ចូររំពឹងគិតអំពីមាគ៌ាជំនាន់ដើម**
**ដើម្បីឲ្យដឹងថា តើមាគ៌ាណាជាមាគ៌ាល្អ**
**រួចនាំគ្នាដើរតាមមាគ៌ានោះទៅ**
**ចិត្តរបស់អ្នករាល់គ្នានឹងបានស្ងប់ » ។[៤០]** ❧

---

(៣៩) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ ម៉ាថាយ ៧:១៣-១៤

(៤០) ដកស្រង់ចេញពីព្រះគម្ពីរព្រះយេស៊ូវ យេរេមា ៦:១៦